# សេចក្តីថ្លែងការណ៍រួម

NGO-CEDAW (មានសមាជិក ៧៩ អង្គការ), GAD net (មានសមាជិក ៥៨ អង្គការ), និង CAMBOW (មានសមាជិក ៣៥ អង្គការ), ជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដែលធ្វើការផ្តោតទៅលើការលើកកម្ពស់សិទ្ធិរបស់ស្ត្រី។ ក្នុងចំណោមមនុស្សដែលបានចាប់ខ្លួនទាំង ២៥ នាក់ ក្នុងនោះពីរនាក់ជាសមាជិក NGO-CEDAW អ្នកទាំងពីរនាក់នេះរួមមានៈ លោក វន់ ពៅ (IDEA) និងលោក ថេង សាវឿន (CCFC)។

យើងខ្ញុំសូមសម្តែងការសាទរចំពោះការសម្រេចរបស់តុលាការក្រុងភ្នំពេញ កាលពីថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០១៤ ដែលបានសម្រេចដោះលែងមនុស្សទាំង ២៥ នាក់ ដែលបានជាប់ពន្ធនាគារអស់រយៈពេលជាង ៥ ខែកន្លងទៅនេះ ដោយគិតចាប់តាំងពីថ្ងៃចាប់ខ្លួនពួកគាត់។ ក៏ប៉ុន្តែយើងខ្ញុំនៅតែមានការសោកស្តាយ ដោយហេតុថាអ្នកទាំង ២៥ នាក់នោះនៅតែត្រូវបានកាត់ឲ្យជាប់ទោស ថ្វីត្បិតតែតុលាការបានសម្រេចព្យួរទោសពួកគាត់ក៏ដោយ និងមិនតែប៉ុណ្ណោះ ពួកគាត់មួយចំនួនត្រូវបានតម្រូវឲ្យបង់ប្រាក់ពិន័យយ៉ាងធ្ងន់ធ្ងរ ក្នុងសេចក្តីសម្រេចជាចុងក្រោយនៃសវនការដែលពោរពេញដោយចំនុចខ្វះខាតជាច្រើននោះ។

យើងខ្ញុំក៏សោកស្តាយផងដែរចំពោះអ្នកដែលត្រូវបានចាប់ខ្លួន និងត្រូវបានកាត់ទោសទាំងនេះ ដោយហេតុថាពួកគាត់មិនគួរត្រូវបានចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន និងកាត់ទោសទាល់តែសោះ។

យើងខ្ញុំក៏មានការសោកស្តាយយ៉ាងខ្លាំង ដោយសារសិទ្ធិស្មើគ្នាចំពោះមុខតុលាការជំនុំជម្រះ មិនត្រូវបានអនុវត្តនៅក្នុងសវនការកន្លងមក។ វិមតិសង្ស័យដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ មិនត្រូវបានយកមកអនុវត្តនៅក្នុងសវនការនោះទេ។ តុលាការហាក់ដូចជាផ្តោតតែទៅលើវត្តមានរបស់ជនជាប់ចោទនៅកន្លែងកើតហេតុ និងចម្លើយមិនស៊ីចង្វាក់គ្នារបស់សាក្សីតែប៉ុណ្ណោះ ជាជាងការផ្តល់ភស្តុតាងច្បាស់លាស់ ក្នុងការចោទប្រកាន់អ្នកទាំងអស់នេះ។

យើងខ្ញុំសង្ឃឹមថា នឹងមានការលើកលែងការចោទប្រកាន់ទាំងអស់នៅពេលដែលរឿងក្តីនេះទៅដល់នីតិវិធី របស់សាលា ឧទ្ធរណ៍។

យើងខ្ញុំក៏សូមអំពាវនាវយ៉ាងទទូចដល់អាជ្ញាធរ សូមលោកមេត្តាបើកការស៊ើបអង្កេត ឲ្យបានហ្មត់ចត់ ដើម្បីស្វែងរកចាប់ខ្លួនជន ល្មើសពិតប្រាកដ និងនាំជនទាំងអស់នេះមកផ្តន្ទាទោសតាមច្បាប់។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤


សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនង:

- លោក **ហេង សំអ៊ិន** អគ្គលេខាធិការសមាគម IDEA និងជាគណ:អចិន្ត្រៃយ៍នៃ NGO-CEDAW
  លេខទូរស័ព្ទ: ០១៥ ៧៧០ ១២០ Email: orn_idea@yahoo.com
- លោកស្រី **រស់ សុភាព** តំណាង GADnet និងនាយិការអង្គការ GADC លេខទូរស័ព្ទ: ០១២ ៦២៧ ៨៥៧
  Email: ed@gadc.org.kh
- កញ្ញា **អ៊ុំ ទេពផល្លីន** អនុប្រធាន CFSWF និងជាគណ:អចិន្ត្រៃយ៍នៃ NGO-CEDAW
  លេខទូរស័ព្ទ: ០១១ ៩៨៤ ៨៨៣/០៩៨ ៩៨៤ ៨៨៣, Email: phallin@cfswf.org
- កញ្ញា **នៅ ស្រីអូន** អ្នកសម្របសម្រួល CAMBOW លេខទូរស័ព្ទ: ០៧៧ ៧២២ ៧២៥
  Email: cambowmail@gmail.com